# ការថែទាំសន្ទូង





នាយកដ្ឋាន ផ្សព្វផ្សាយកសិកម្ម

លេខ : ៣ ឆ្នាំ ២០០២

ការថែទាំគឺជាការងារមួយចាំបាច់បំផុតក្នុងផលិតកម្មដំណាំស្រូវ ។ ដូច្នេះដើម្បីឱ្យដំណាំស្រូវដុះលូតលាស់ល្អនិងផ្តល់ទិន្នផលខ្ពស់គួរគប្បីធ្វើការថែទាំសន្ទូងជាប្រចាំ ។

## ១- ការគ្រប់គ្រងទឹក :

ការគ្រប់គ្រងទឹកបានត្រឹមត្រូវ គឺធ្វើឱ្យស្រូវដុះលូតលាស់បានល្អ ហើយអាចកាត់បន្ថយនូវការបាត់បង់ទិន្នផលដែលបណ្តាលមកពីការរាំងស្ងួតនិងស្មៅចង្រៃ ។ សំរាប់កន្លែងដែលមានភ្លៀងពុំសូវទៀងទាត់ ហើយធាប់រាំងស្ងួតនោះគួរគប្បីគិតគូរលើកក្តាសំខាន់ៗដូចជា :

- ថែទាំភ្លឺស្រែអោយបានល្អ ដើម្បីរក្សាទឹក និងកាត់បន្ថយការហូរច្រោះនិងការបាត់បង់ជីជាតិ ។
- ត្រូវរក្សាកំរិតទឹក ២ - ៣ ស.ម ឬ ២ - ៣ ហ៊ុន អោយបានថេរ រហូតដល់ពេលស្រូវចាប់ផ្តើមលូតលាស់ ទើបបន្ថែមទឹកទៅតាមប្រភេទពូជស្រូវដែលស្ទូង ។
- ទឹកដែលបញ្ចូលក្នុងស្រែ បន្ទាប់ពីស្ទូងរយ:ពេល ៧ - ១០ ថ្ងៃ កសិករតែងតែអនុវត្តន៍បង្ហូរទឹកចេញទុករយ:ពេល ១- ២ថ្ងៃ ដើម្បីទុកឱ្យមានខ្យល់ចេញ

ចូលក្នុងដីធ្វើឱ្យសន្ទូងបែកគុម្ពបានល្អ ។

- ត្រូវរក្សាទឹកក្នុងស្រែអោយបានគ្រប់គ្រាន់ នៅដំណាក់កាលស្រូវផើម និងដាក់ទឹកដោះ ព្រោះបើមានការរាំងស្ងួតក្នុងដំណាក់កាលនេះ នាំឱ្យស្រូវស្កកនិងបាត់បង់ទិន្នផលច្រើន ។

- មុនពេលច្រូតកាត់ ១ - ២ សប្តាហ៍ត្រូវបង្ហូរទឹកចេញពីស្រែ ដើម្បីបង្កើនល្បឿននៃការទុំអោយបានឆាប់រហ័ស ។

បើសិនធ្វើទៅបាន គួរជីកស្រះក្នុងស្រែទំហំ ២០ ម x ១០ ម ដើម្បីផ្ទុកទឹកសំរាប់ស្រោចស្រពនៅពេលរាំងស្ងួតនិងអាចចិញ្ចឹមត្រីផងដែរ ។

ការថែរក្សាទឹកក្នុងស្រែនេះធ្វើឡើងដើម្បី :

- កុំឱ្យស្មៅចង្រៃដុះ

- ងាយស្រួលដល់ស្រូវក្នុងការស្រូបយកជីជាតិពីក្នុងដី ។

- ជួយរំលាយសារធាតុជីសរីរាង្គនិងជីគីមី ឬ ថ្នាំគីមីមានសណ្ឋានជាគ្រាប់ ។

## ២- ការកំចាត់ស្មៅ :

គឺត្រូវកំចាត់ស្មៅដែលដុះលាយឡំជាមួយនឹងស្រូវរបស់យើងឱ្យបានស្អាតមុនពេលបាចជី ។ ព្រោះស្មៅ វាប្រជែងដណ្តើមស្រូបយកជីជាតិ សំណើម និងជាជំរកសំរាប់សត្វល្អិតចង្រៃ ។

## ៣- ការបាចជីបំប៉ន :

ការបាចជីបំប៉ន គឺត្រូវធ្វើក្រោយពេលស្ទូងជាដំណាក់ៗ គេប្រើជា២ដំណាក់កាលរបស់ស្រូវ ។ ចំពោះស្រូវដែលមានអាយុកាលខ្លី ឬ អាយុកាលមធ្យមគេប្រើជីបំប៉នជា ២ លើក :

- លើកទី ១ : ក្រោយពេលស្ទូងរយៈពេល ១៥ ថ្ងៃ ។

- លើកទី ២ : ក្រោយពេលស្ទូងរយៈពេល ៤៥ ទៅ ៤៧ ថ្ងៃ ។

## ៤- សត្វល្អិតចង្រៃ :

ក្នុងវគ្គលូតលាស់របស់ដំណាំស្រូវយើងតែងតែជួបប្រទះនូវពពួកសត្វល្អិតចង្រៃដែលបំផ្លាញជាញឹកញាប់ជាងគេនោះគឺ :

- ដង្កូវបំពង់កាត់ស្លឹក

- ដង្កូវស៊ីរូងដើម

## ៥- វិធានការការពារនិងកំចាត់ :

- ស្ទូងសំណាបចាស់

- ពន្លិចទឹកក្នុងស្រែរួចកៀរបំពង់ដង្កូវយក

ដុតចោល ។

- បង្ហូរទឹកចេញពីក្នុងស្រែឱ្យអស់ពី ២ ទៅ ៣ ថ្ងៃ ដើម្បីឱ្យដង្កូវកប់ភក់ងាប់ ។

- ថែរក្សាសត្វមានប្រយោជន៍ ពន្លិចទឹកសន្ទូងដើម្បីកៀរដង្កូវចេញ ។

- ប្រើថ្នាំសំលាប់ ក្នុងករណីយើងសង្កេតឃើញស្លឹកស្រូវបំផ្លាញមានច្រើន ។

- ប្រើថ្នាំគីមីក្នុងករណីដែលវាបំផ្លាញខ្លាំង


<u>រៀបរៀងដោយ</u>

ភ្នាក់ងារប្រតិបត្តិទី២ ( ការងារផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្ម)
នៃគំរោងឥណទានកម្មវិធី របស់ធនាគារអភិវឌ្ឍន៍អាស៊ី
ADB, Loan No. 1445 CAM (SF)

<u>អាសយដ្ឋាន</u> : លេខ ២០០ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ